**សកម្មភាព** ៖ **សូនរូបមេរោគដោយដីឥដ្ឋ**

**ចិត្តចលភាព**

បំណិនចលកតូច (ការហ្វឹកហាត់បង្កើនកម្លាំង សម្របសម្រួលសាច់ដុំដៃ និងភ្នែកសាច់ដុំភ្នែក)។

**វិទ្យាសាស្ត្រ**

បំណិនអនាម័យ (ទម្លាប់រស់នៅមានអនាម័យក្នុងគ្រួសារ និងសង្គម)

**សិក្សាសង្គម**

គំនូរនិងសកម្មភាពកសាង(ការយល់ដឹងនិងការពេញចិត្តចំពោះសិល្បៈតាមរយៈការបង្កើតរូបភាព)

**គោលបំណង** ៖

**(ចិត្តចលភាព)** ប្រាប់ពីរបៀបធ្វើចលនាដៃតាមទម្រង់ផ្សេងៗដោយការធ្វើអ្វីមួយ ឬ លេងល្បែង។

**(វិទ្យាសាស្ត្រ)** ប្រាប់ពីទម្លាប់ល្អទាំងឡាយ មុន និងក្រោយពេលញ៉ាំអាហារ បន្លែ ផ្លែឈើ ទឹកស្អាត ចូលបង្គន់អនាម័យ សម្អាតខ្លួនប្រាណ ។

**(សិក្សាសង្គម)** ប្រាប់បានពីរបៀបធ្វើសកម្មភាពដើម្បីបង្កើតបានជារូបភាពផ្សេងៗ។

**សៀវភៅ** ៖ ដកស្រង់ចេញពីរឿង "បិសាចចម្លែកតូចៗ" ។

**កម្រិត** ៖ មធ្យម ទាប ខ្ពស់

**រយៈពេល** ៖ ៣០ នាទី

**ឧបករណ៍** ៖ ដីឥដ្ឋ សម្ភារសម្រាប់ធ្វើភ្នែក កាវ គម្រូដែលបានធ្វើរួច សម្រាប់បង្ហាញឱ្យក្មេងៗមើល ។

**ការរៀបចំ** ៖ ធ្វើដីឥដ្ឋសម្រាប់សូនរូប បោះពុម្ពរូបភ្នែក ធ្វើការម៉្យៅ ប្រមែប្រមូលរបស់របរសម្ភារមួយចំនួនដែលអាចប្រើសម្រាប់ដោត ចាក់ ដូចជា ទុយោរ ឈើចង្កឹះតូចៗ និងសម្ភារផ្សេងៗ។ បង្កើតជាគម្រូរសម្រាប់បង្ហាញដល់ក្មេងៗ។

**សេក្តីណែនាំ៖**

1. ថ្ងៃនេះអ្នកគ្រូនឹងលេងល្បែង**សូនរូបមេរោគដោយដីឥដ្ឋ**ជាមួយកូនៗទាំងអស់គ្នា។
2. សួរក្មេងៗ៖ តើកូនៗស្គាល់មេរោគដែរឬទេ? បាទ/ចាស ស្គាល់។

   តើមេរោគមានរូបរាងយ៉ាងដូចម្តេច? បាទ/ចាស តូចៗមើលមិនអាចមើលឃើញនោះទេ។

តើដើម្បីកំចាត់មេរោគកូនៗត្រូវធ្វើដូចម្តេច? បាទ/ចាស លាងដៃជាមួយសាប៊ូ និងទឹកមុនពេល និងក្រោយពេលញ៉ាំអាហារ មុន និងក្រោយពេលចូលបង្គន់ សម្អាតខ្លួនប្រាណ…..។

3. បង្ហាញក្មេងៗពីឧទាហរណ៍ និងពន្យល់របៀបធ្វើវា និងប្រាប់ពីសេចក្តីណែនាំដូចខងក្រោមៈ
    - រូបរាង ដីឥដ្ឋ
    - បិទការនៅលើភ្នែក
    - ចាក់វត្ថុមួយចំនួននោះទៅលើដីឥដ្ឋដែលបានធ្វើវាឡើង ជាមេរោគ ឬជាបិសាចតូចៗ។
4. ប្រាប់ក្មេងៗៈកូនៗនឹងធ្វើការរួមគ្នាជាក្រុមដើម្បីបង្កើតរូបមេរោគ ឬបិសាចតូចៗដោយប្រើដីឥដ្ឋ។
5. បែងចែកក្មេងៗទាំងអស់ទៅជាក្រុមៗ ។
6. អ្នកគ្រូចង់ឱ្យកូនៗទាំងអស់ធ្វើការងារជាក្រុម ដូច្នេះហើយសមាជិកក្រុមទាំងអស់ បង្កើតរូបមេរោគដូចៗគ្នា។ ពួកគេត្រូវសម្រេចចិត្តថាប្រើអ្វីសម្រាប់ចាក់ចូលទៅក្នុងដីឥដ្ឋ (ដាក់ភ្នែកមុនគេបានល្អ)។ នៅពេលដែលក្មេងណាម្នាក់បានសម្រេចចិត្តថានឹងប្រើអ្វីធ្វើវា ក្មេងៗទាំងអស់នៅក្នុងក្រុមត្រូវធ្វើឱ្យដូចគ្នា។
7. តាមវិធីនេះដែរ ក្រុមនីមួយៗនឹងធ្វើរូបមេរោគខុសគ្នាក៏បានដែរ។ ប៉ុន្តែរូបមេរោគនៅក្នុងរូបនីមួយៗនឹងដូចគ្នា។
8. ចែកដីឥដ្ឋឱ្យទៅក្មេងៗ ភ្នែក ការ និងវត្ថុសម្រាប់ចាក់លើដីឥដ្ឋ។
9. ចូរឱ្យក្មេងៗបែងចែកដីឥដ្ឋឱ្យសមាជិកក្រុមម្នាក់ បន្ទាប់មកចាប់ផ្តើមលេង ។
10. រំលឹកពួកគេ ថានៅពេលដល់វេនសម្រេចចិត្តពួកគេគួរតែពន្យល់ដោយប្រយ័ត្នប្រយែងថាត្រូវដាក់វត្ថុនោះនៅកន្លែងណា។
11. នៅពេលដែលមិនមែនជាវេនរបស់ពួកគេពួកគេគួរតែស្តាប់ដោយយកចិត្តទុកដាក់ចំពោះការណែនាំរបស់កុមារដទៃទៀតហើយធ្វើតាម។
12. នៅពេលដែលពួកគេធ្វើរួចរាល់ហើយនោះ ប្រាប់ពួកគេថាត្រូវដាក់រូបនៅទីណា ដើម្បីឱ្យវឆាប់ស្ងួត។
13. ប្រសិនបើមានពេលក្នុងការលេងទៀត សូមឱ្យពួកគេធ្វើដោយខ្លួនឯងម្តងទៀត ។
14. នៅពេលដែលពួកគេបានលេងល្បែងនេះចប់ហើយនោះ ចូរឱ្យពួកគេរៀបចំឱ្យបានស្អាត និងបោះចោលសម្រាមឱ្យមានរបៀបរៀបរយផងជាការស្រេច។





